Faculty Publications
Vol 3, No 2, July - December 2018, pp: 101 - 108
License: CC BY 4.0

**Faculty Publications**
ISSN: 3008-1017
Title DOI: https://doi.org/10.62458/021024

# A Note on Legal Methods: Recent Caselaw in Cambodia

## Virak Prum*

### Abstract

This article begins with a glance at what generally distinguishes public law from private law, then highlights the chief different origins of two main western legal traditions: common law and civil law. Although traditionally belonging to the civil law tradition, parts of Cambodian legal system have increasingly adopted and applied *stare decisis* legal method found in the common law too. This adoption is evidenced in the way the Arbitration Council (labor) has developed its jurisprudence over the years. I believe that the influence of *stare decisis* will steadily increase in Cambodia.

**Keywords:** common law; civil law; jurisprudence.

* Virak Prum, PhD
CamEd Business School
Email: pvirak@cam-ed.com

## ភាពខុសគ្នារវាងនីតិសាធារណៈ និង នីតិឯកជន

យើងគួរពិនិត្យចរិកលក្ខណៈចំបងដែលញែកនីតិសាធាណៈពីនីតិឯកជន។ នីតិឯកជនត្រូវបានប្រើក្នុងពេលមានជំលោះរវាងភាគីឯកជនដែលក្នុងនោះ ចៅក្រមត្រូវសម្រេចវិវាទដោយឈរលើភស្តុតាងដែលភាគីនីមួយៗបានដាក់មក។ ក្នុងការធ្វើសេចក្តីសម្រេចចៅក្រមតែងគោរពតាមលំនាំនៃសេចក្តីសម្រេចមុនៗដែល គេហៅថា “យុត្តិសាស្រ្ត” (jurisprudence) ឬតាមច្បាប់ដែលកំណត់អំពីព្រំដែននៃសេចក្តីសម្រេចនោះ។ ចំនែកឯនីតិសាធារណៈទាក់ទងទៅនឹងទង្វើរបស់អាជ្ញាធរសាធារណៈ ក្នុងការគ្រប់គ្រងអំពើរបស់បុគ្គលទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលដោយពឹងផ្អែកលើបញ្ញត្តិច្បាប់ដើម្បីធានាការការពារប្រយោជន៍សាធារណៈ។ ទោះបីជាក្នុងការចេញសេចក្តីសម្រេចណាមួយអាជ្ញាធរសាធារណៈពេលខ្លះត្រូវផ្តល់សិទ្ធិដល់គូភាគីអោយចូលបំភ្លឺក៏ដោយ ក៏នីតិវិធីនេះពុំមានលក្ខណៈស្មុគស្មាញដូចនីតិវិធីដែលចៅក្រមប្រើក្នុងរឿងវិវាទក្រោមនីតិឯកជនដែរ ពោលគឺអ្នករដ្ឋបាលតែងមានអំណាចឆន្ទានុសិទ្ធិមួយចំនួនដោយសារ ច្បាប់ច្រើនបានធ្វើប្រតិភូកម្មអំណាច (ផ្តល់អំណាច)ដល់អាជ្ញាធរ ដើម្បីចេញសេចក្តីសម្រេចទៅតាមគោលដៅរបស់អាជ្ញាធរនោះ។ម្យ៉ាងទៀត សេចក្តីសម្រេចរបស់អ្នករដ្ឋបាលក៏ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាល និង ការត្រួតពិនិត្យរបស់សភាជាដើម។[2]

ជាការពិតណាស់ ការបែងចែកនីតិសាធារណៈ និង នីតិឯកជនពុំមានលក្ខណៈដាច់ខាតនោះទេ។ ជាក់ស្តែងក្នុងសហរដ្ឋអាមេរិកជាដើមទោះជាភារៈកិច្ចក្នុងការអនុវត្តច្បាប់ ជាភារៈកិច្ចរបស់អាជ្ញាធររដ្ឋបាលក៏ដោយ ក៏ពេលខ្លះ ចៅក្រមក៏ត្រូវទទួលភារៈកិច្ចនេះដែរ ឧទាហរណ៍ ច្បាប់ Sherman Act នៅអាមេរិកផ្តល់អំណាចដល់តុលាការសហព័ន្ធក្នុងការអនុវត្តការហាមឃាត់មិនអោយមានភាពផ្តាច់មុខ និង គំនាបលើវិស័យពាណិជ្ជកម្ម។ ម្យ៉ាងវិញទៀត ទោះបីជាអាជ្ញាធររដ្ឋបាលជាអ្នកមានតួនាទីចំបង ក្នុងការអនុវត្តច្បាប់ក៏ដោយ ក៏តុលាការនៅមានតួនាទីក្នុងការពិនិត្យនីត្យានុកូលភាព(ភាពស្របច្បាប់)ចំពោះសេចក្តីសម្រេចដែរ។ ក្នុងន័យនេះគេអាចនិយាយបានថា តុលាការពុំមែនមានសិទ្ធិត្រឹមតែការពារ និង អនុវត្តការគោរពសិទ្ធិឯកជនប៉ុណ្ណោះទេ តុលាការក៏ចូលរួមចំណែកក្នុងការអនុវត្តនីតិសាធារណៈផងដែរ។

ម៉្យាងទៀតនៅប្រទេសដែលតុលាការមានតួនាទីក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់[3] គេឃើញមានសេចក្តីសម្រេចរបស់តុលាការជាច្រើនដែលគ្រប់គ្រងគោលនយោបាយសំខាន់ៗស្ទើរគ្រប់វិស័យដូចជាវិស័យអប់រំ វិស័យសុខាភិបាល ការប្រើអំណាចប៉ូលីស ឬសិទ្ធិមានទីជម្រកជាដើម។ រីឯមុខងារមួយចំនួនដែលជាទូទៅធ្លាប់ស្ថិតនៅក្រោមនីតិសាធារណៈ ក៏ត្រូវបានប្រគល់អោយមក បុគ្គលឯកជនជាអ្នកធ្វើដែរ ឧទាហរណ៍ដូចជា ការប្រើអ្នកជាប់កិច្ចសន្យា “Private Contractors” អោយទៅកាន់អាវុធចូលធ្វើសង្គ្រាមនៅអ៊ីរ៉ាក់ជាដើម។ ក្នុងករណីបែបនេះ តុលាការត្រូវសម្រេចថាតើ ត្រូវប្រើនីតិសាធារណៈ ឬ នីតិឯកជនក្នុងពេលមានវិវាទកើតឡើង។[4]

---

[2] ទទួលខុសត្រូវក្រោមរដ្ឋាភិបាលក្នុងរូបភាពនៃការគោរពឋានានុក្រម។ ដោយសារក្នុងប្រទេសដែលប្រកាន់របប សភានិយម រដ្ឋាភិបាលត្រូវទទួលខុសត្រូវមុខសភា ដូចនេះរដ្ឋបាលក៏ទទួលខុសត្រូវចំពោះមុខសភាដែរ ទោះដោយប្រយោលក៏ដោយ។ ដោយឡែកក្នុងករណីមួយចំនួន ដែលសភាបង្កើតស្ថាប័នណាមួយនោះ ក៏គេសង្កេតឃើញស្ថាប័ននោះត្រូវទទួលខុសត្រូវចំពោះសភាផ្ទាល់ដែរ។

[3] នៅកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នមានអំណាចសម្រេចបិទផ្លូវតវ៉ាលើបណ្តឹងសុំពិនិត្យធម្មនុញ្ញភាពនេះ។

[4] Paul Verkeuil (2006) “Private Law Limitations on Privatization of Government Functions,” 84, N.C.L. Review.

## ប្រវត្តិនៃការបែងចែកនីតិសាធារណៈ និង នីតិឯកជន

តាំងពីសម័យព្រះចៅអធិរាជ Justinian បណ្ដារដ្ឋដែលប្រកាន់យកប្រព័ន្ធច្បាប់ Civil Law តែង បែងចែកនីតិសាធារណៈដាច់ពីនីតិឯកជនដែលការបែងចែកនេះ ឈរលើមូលដ្ឋានបីជាចំបង៖ ការរៀបចំអំណាចតុលាការចរិកលក្ខណៈរបស់ទស្សនៈវិជ្ជាច្បាប់ និងការបណ្ដុះបណ្ដាល ក្នុងវិស័យច្បាប់។

រដ្ឋដែលប្រកាន់យកប្រព័ន្ធ Civil Law ច្រើនប្រើប្រព័ន្ធតុលាការពីរដាច់ពីគ្នា ពេលជំនុំជម្រះលើវិវាទដែលស្ថិតនៅក្រោមនីតិសាធារណៈ និង វិវាទដែលស្ថិតនៅក្រោមនីតិឯកជន។ នីតិឯកជនដែលភាគច្រើន ទាក់ទិននឹងវិស័យពាណិជ្ជកម្ម និង វិស័យរដ្ឋប្បវេណី[5] ត្រូវដោះស្រាយដោយតុលាការធម្មតាក្នុងខណៈដែលវិវាទក្រោមនីតិសាធារណៈដែលភាគច្រើនទាក់ទិនទៅនឹងវិស័យរដ្ឋបាល និងរដ្ឋធម្មនុញ្ញត្រូវដោះស្រាយដោយតុលាការរដ្ឋបាល ឬ តុលាការពិសេស។ តុលាការរដ្ឋបាល ឬ តុលាការពិសេស នេះមានអំណាចធ្វើមោឃភាព (លុបចោល) នូវសេចក្ដីសម្រេចរដ្ឋបាលដែលខុសច្បាប់ដោយសារមូលហេតុ ភ័ន្តច្រឡំលើព្រឹត្តិហេតុ ឬ ភ័ន្តច្រឡំលើគតិច្បាប់ ក៏ដូចជាករណីដែលកើតចេញពីការរំលោភឆន្ទានុសិទ្ធិជាដើម។[6] នៅក្នុងប្រព័ន្ធនេះ ចៅក្រមតែងមានឯកទេសក្នុងនីតិរដ្ឋបាល ព្រមទាំងមានការបែងចែកតាមជំនាញនីមួយៗថែមទៀត ដូចជា ជំនាញពន្ធដារ ជំនាញសន្តិសុខសង្គមជាដើម។

សម្រាប់បណ្ដាប្រទេសអឺរ៉ុបដែលប្រកាន់យកប្រព័ន្ធ Civil Law គេមានការបែងចែកច្បាស់រវាងនីតិសាធារណៈ និង នីតិឯកជនក្នុងន័យថា នីតិឯកជនសំដៅការការពារកម្មសិទ្ធិឯកជន និង សេរីភាពក្នុងការធ្វើកិច្ចសន្យា។ និយាយម្យ៉ាងទៀត តួនាទីរបស់រដ្ឋ គឺត្រូវធានាឲ្យមានការទទួលស្គាល់នូវកម្មសិទ្ធិឯកជន និង សិទ្ធិចុះកិច្ចសន្យាដែលតាមរយៈនេះរដ្ឋបំពេញភារកិច្ចជាចៅក្រមអព្យាក្រឹត្យក្នុងពេលដោះស្រាយវិវាទរវាងភាគីឯកជន។ ផ្ទុយទៅវិញ នីតិសាធារណៈមានគោលដៅការពារប្រយោជន៍សាធារណៈ។ ហេតុនេះហើយដោយសាររដ្ឋជាស្ថាប័នដែលការពារផលប្រយោជន៍សាធារណៈ រដ្ឋពុំដើរតួជាចៅក្រមអព្យាក្រឹត្យសុទ្ធសាធទេ តែត្រូវតាំងខ្លួនជាភាគីមួយដែរ ប៉ុន្តែក្នុងតួនាទីជាអ្នកការពារផលប្រយោជន៍សាធារណៈនេះ គេតែងសន្មតថាផលប្រយោជន៍របស់រដ្ឋត្រូវមានតម្លៃខ្ពស់ជាងផលប្រយោជន៍ឯកជន។[7]

គោលគំនិតទស្សនវិជ្ជាច្បាប់របស់ទ្វីបអឺរ៉ុបដែលប្រកាន់យក Civil Law អាចឈរលើការបែងចែងរវាងនីតិសាធារណៈ និង នីតិឯកជន ដើម្បីពន្យល់ពីគោលការណ៍បែងចែកអំណាចដែលស្ដែងថាមែកធាងទាំងបីនៃអំណាចត្រូវមានតួនាទី និង ភារកិច្ចដាច់ដោយឡែកពីគ្នា។ ក្នុងន័យនេះហើយ ដែលគេអាចនិយាយបានថា ការដោះស្រាយវិវាទដោយប្រើប្រព័ន្ធតុលាការពីរដោយមានតុលាការរដ្ឋបាល ឬ តុលាការពិសេសផ្សេងនោះ គឺដើម្បីសម្រេចឲ្យបាននូវគោលការណ៍បែងចែកអំណាចនេះឯង។ ដូចនេះ ក្នុងប្រទេសដែលប្រើប្រព័ន្ធតុលាការតែមួយខ្សែទ្រឹស្ដីនៃការបែងចែកអំណាចអាចនឹងពុំមានលក្ខណៈដាច់ខាតដូចប្រទេសដែលប្រើប្រព័ន្ធតុលាការពីរខ្សែរទេ។

នៅក្នុងប្រទេសដែលប្រើប្រព័ន្ធ Common Law ឯណោះវិញ ការបែងចែករវាងនីតិសាធារណៈ និង នីតិឯកជន ពុំសូវមានឥទ្ធិពលខ្លាំងក្លាទេ ដោយសារកាលពីសម័យអង់គ្លេសនៅប្រើអំណាចសក្តិភូមិ សិទ្ធិដែលកើតចេញពីនីតិសាធារណៈ និង សិទ្ធិដែលកើតចេញពីនីតិឯកជន ឈរលើគោលការណ៍ការពារផលប្រយោជន៍កម្មសិទ្ធិ ដោយពុំមានបែងចែកភាពខុសគ្នារវាងកម្មសិទ្ធិរបស់បុគ្គលឯកជន និង កម្មសិទ្ធិរបស់អាជ្ញាធរសាធារណៈឡើយ។ ម្យ៉ាងទៀត អង់គ្លេសដែលជាប្រភពនៃ Common Law ប្រើប្រព័ន្ធតុលាការតែមួយខ្សែរដែលមានអំណាចត្រួតពិនិត្យសកម្មភាពរបស់អាជ្ញាធរសាធារណៈ ក៏ដូចជាក្នុងការដោះស្រាយវិវាទឯកជន។ ដោយឡែកនៅសហរដ្ឋអាមេរិក អ្នកទ្រឹស្ដីច្បាប់ក៏ពុំគិតថាការបែងចែករវាងនីតិទាំងពីរនេះមានសារៈសំខាន់ណាស់ណាដែរ ទោះបីជាមានអ្នកទ្រឹស្ដីមួយចំនួនបានព្យាយាមសរសេរគាំទ្រការបែងចែកនេះក៏ដោយ។ ជាក់ស្ដែងក្នុងការពន្យល់ពីការវិវឌ្ឍដែលកើតមានឡើងក្នុងនីតិរដ្ឋបាល ក៏ដូចជាក្នុងនីតិរដ្ឋធម្មនុញ្ញ សាស្ត្រាចារ្យ Mashaw ធ្វើការប្រៀបធៀបរវាងគោលការណ៍នីតិរដ្ឋ (នីតិសាធារណៈ) និងសិទ្ធិប្ដឹងពីនីត្យានុកូលភាពនៃសេចក្ដីសម្រេចរបស់អាជ្ញាធរសា

[5] វិស័យរដ្ឋប្បវេណីគ្របដណ្ដប់បញ្ហាទាក់ទងនឹងកិច្ចសន្យានានា ទ្រព្យសម្បត្តិ បណ្ដាំ(មរតក) គ្រួសារ និងសាច់ញាតិជាដើម។

[6] ដើម្បីព័ត៌មានបន្ថែមសូមអាន Yves Gaudemet (2015), p.133-162..

[7] ដើម្បីព័ត៌មានបន្ថែមសូមអាន Jean Waline (2016) *Droit Administratif*, 26 edi (Précis). Paris: Dalloz.

ធារណៈដែលឈរលើគោលការណ៍ឯកបុគ្គល (នីតិឯកជន) ។[8] ចៅក្រមក៏ប្រើការបែងចែករវាងនីតិទាំងពីរនេះ នៅពេលដោះស្រាយវិវាទទាក់ទងនឹងរដ្ឋធម្មនុញ្ញ ជាពិសេសវិវាទអំពីសិទ្ធិទទួលបាននូវដំណោះស្រាយតាមផ្លូវតុលាការ និង តួនាទីរបស់តុលាការក្នុងទ្រឹស្តីប្រជាធិបតេយ្យដែលទទួលស្គាល់អំណាចរបស់អ្នកតំណាងរាស្ត្រក្នុងការធ្វើច្បាប់។ ជាការគាំទ្រទ្រឹស្តីនេះ រឿងក្តី Chevron ឆ្នាំ១៩៨៤ បានចេញយុត្តិសាស្ត្រថ្មីដែលចែងថា ចៅក្រមដែលមិនកើតចេញពីការបោះឆ្នោតពុំមែនជាសមាជិកនៃស្ថាប័ននយោបាយទេ។[9]

ការបណ្តុះបណ្តាលវិស័យច្បាប់ក្នុងប្រព័ន្ធ Civil Law ច្រើនផ្តោតសារៈសំខាន់ទៅលើទ្រឹស្តីរបស់ អ្នកប្រាជ្ញ និង សាស្ត្រាចារ្យល្បីៗដែលគេហៅថា “la doctrine” នេះក៏ព្រោះតែសាកលវិទ្យាល័យបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀន Civil Law នៅទ្វីបអឺរ៉ុប ក្នុងខណៈដែលនីតិសាស្ត្រក្នុងប្រព័ន្ធ Common Law មានមូលដ្ឋាននៅលើការវិភាគសេចក្តីសម្រេច (យុត្តិសាស្ត្រ)របស់តុលាការ។

## ដើមកំនើតប្រព័ន្ធ Common Law និង ប្រព័ន្ធ Civil Law [10]

### ប្រព័ន្ធ Common Law

ប្រព័ន្ធ Common Law មានដើមកំនើតនៅអង់គ្លេស។ នៅឆ្នាំ ១០៦០ ស្តេចឈ្មោះ William បានចូលទន្ទ្រានប្រទេសអង់គ្លេស ហើយអនុវត្តគោលនយោបាយកែលំអច្បាប់អង់គ្លេសជាបណ្តើរៗ។ ប៉ុន្តែ William យកចិត្តទុកដាក់មិនចង់អោយប្រជាជនអង់គ្លេសចាត់ទុកទ្រង់ជាអ្នកឈ្លានពានទេ តែចង់អោយគេចាត់ទុកទ្រង់ជាក្សត្របន្តរាជ្យដោយសន្តិភាព។ ក្នុងគោលនយោបាយបន្តនិរន្តរ៍ភាពនេះ William មិនបំបាត់ចោលនូវប្រពៃណីទំនៀមទំលាប់ និង ប្រព័ន្ធតុលាការដែលមានស្រាប់នៅអង់គ្លេសឡើយ បានន័យថា តុលាការតាមតំបន់នីមួយៗនៅបន្តធ្វើសេចក្តីសម្រេចទៅតាមទំនៀមទំលាប់ពីដើមរៀងៗខ្លួន។ និយាយម្យ៉ាងទៀត ប្រទេសអង់គ្លេសពុំមានប្រព័ន្ធច្បាប់ឯកភាពតែមួយទេ។ បន្ទាប់មក William ក៏បង្កើតនូវក្រុមចៅក្រមក្នុងរាជវាំង Westminster ដែលចាប់ផ្តើមពីយុត្តាធិការដែលគ្របដណ្តប់លើប្រភេទរឿងក្តីមួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែយុត្តាធិការនេះ បានពង្រីកគ្របដណ្តប់លើរឿងក្តីផ្សេងៗ រហូតដល់ឥទ្ធិពលរបស់តុលាការតាមតំបន់ត្រូវបានសាបរលាភជាបណ្តើរៗ។ សេចក្តីសម្រេចរបស់ក្រុមចៅក្រមក្នុងរាជវាំងនេះ ក៏ក្លាយជាប្រភពនៃច្បាប់សម្រាប់យកទៅអនុវត្តដូចគ្នានៅគ្រប់ទិសទីនៅប្រទេសអង់គ្លេស។ ចលនានេះ បានបង្កើតជាបណ្តើរៗនូវប្រព័ន្ធច្បាប់មួយដែលទទួលបានការអនុវត្តដូចៗគ្នា (common) ចំពោះរឿងក្តីស្រដៀងគ្នា។ នេះ ហើយជាអ្វីដែលគេហៅថា Common Law។

ក្នុងការអនុវត្តន៍ ចំពោះរឿងក្តីស្រដៀងគ្នាចៅក្រមត្រូវគោរពតាមសេចក្តីសម្រេចមុនៗ។ ប៉ុន្តែនៅពេលដែលសេចក្តីសម្រេចនេះកកើតកាន់ច្រើនឡើងៗធ្វើអោយស្តេចមានការបារម្ភណ៍ខ្លាចប៉ះពាល់ដល់អំណាចខ្លួន ដែលជាហេតុញ៉ាំងអោយស្តេចបង្កើតក្រុមតុលាការបន្ថែមទៀត ក្នុងគោលបំណងបង្កើតទ្រឹស្តីថ្មី។ តុលាការថ្មីនេះមានឈ្មោះថា Court of Chancery ដែលមានអំណាចទទួល និង ដោះស្រាយញត្តិពីប្រជាជនដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់តុលាការ Common Law ។ Court of Chancery ចេញសេចក្តីសម្រេចដើម្បីផ្តល់នូវសមធម៌ “Equity” ដែលគេជឿថាអាចកែកំហុសរបស់ច្បាប់បាន។ សេចក្តីសម្រេចផ្អែកលើច្បាប់ និង សមធម៌ទាំងនេះជាមូលដ្ឋានរបស់ Common Law ដែលវិវត្តន៍មកដល់សព្វថ្ងៃ។ ប្រទេសធំៗ មួយចំនួនដែលប្រើប្រព័ន្ធ Common Law សព្វថ្ងៃរួមមានសហរដ្ឋអាមេរិក អូស្ត្រាលី ញូវសេឡែន កាណាដា (លើកលែងតំបន់ Quebec) ជាដើម។

---

[8] Mashaw J (1983) *“Rights” in the Federal Administrative State*, 92 Yale Law Journal.

[9] Chevron U.S.A., Inc. v. Natural Resources Defense Council Inc., 467 U.S. 837 (1984).

[10] អត្ថបទដកស្រង់ពី Jane Ginsburg (2014) *Legal Methods*. Foundation Press (University casebook series).

## ប្រព័ន្ធ Civil Law

ប្រព័ន្ធ Civil Law បានចាប់កំណើតប្រហែលក្នុងសតវត្សទី ៥ មុនគ្រិស្តសករាជ នៅអាណាចក្ររ៉ូម៉ាំង ដែលកាលនោះ មានឈ្មោះថា "សិក្ខាបទទាំងដប់ពីររបស់សាធារណៈរដ្ឋរ៉ូម៉ាំង"។ សិក្ខាបទ ឬ ច្បាប់នេះ ដំបូងឡើយអនុវត្តតែចំពោះ "ពលរដ្ឋ" (ភាសាឡាតាំង "civis") របស់ទីក្រុងរ៉ូមប៉ុណ្ណោះ ដែល ខុសពីច្បាប់សម្រាប់អនុវត្តចំពោះជនមិនមែនជាពលរដ្ឋ។ ដូចនេះពាក្យថា Civil Law (ក្នុងភាសាឡាតាំង "Jus civilis") សំដៅលើច្បាប់របស់ពលរដ្ឋរ៉ូម៉ាំងនេះឯង។ បន្ទាប់ពីអាណាចក្ររ៉ូម៉ាំងបានដួលរលំ នៅឆ្នាំ ៤៧៦ នៃគ្រិស្តសករាជ ក្រុមយង់ឃ្នង ("Barbarians") ចូលលុកលុយទីក្រុងរ៉ូម និងបាននាំយកច្បាប់ទម្លាប់របស់ខ្លួនមកជាមួយដែរ តែពួកនេះ នៅបន្តប្រើ Civil Law សម្រាប់អនុវត្តលើជនជាតិរ៉ូម៉ាំងដដែល។ ឥទ្ធិពលរបស់ពួកយង់ឃ្នង ឬ អាឡឺម៉ង់ បានរីកដុះដាលយ៉ាងឆាប់រហ័ស នៅលាយឡំគ្នាជាមួយច្បាប់រ៉ូម៉ាំងដើម។ ក្រោយមកទៀតក្នុងចន្លោះឆ្នាំ ៥២៩ ដល់ ៥៣៤ នៃគ្រិស្តសករាជ ព្រះចៅអធិរាជក្រុងរ៉ូមឈ្មោះ Justinian បានបោះពុម្ពក្រមមួយឈ្មោះថា "Corpus Juris Civilis" ដែលជាបណ្តុំច្បាប់ដោយឈរលើមូលដ្ឋានច្បាប់ និង ឯកសារចាស់ពីដើម។ ក្រម Justinian នេះបន្តអានុភាពអនុវត្តយ៉ាងហោចណាស់រហូតដល់សតវត្សទី ១៥ នៅពេលជនជាតិទួគីអូតូម៉ង់ (Ottoman Turks) ចាប់ផ្តើមវាយទន្ទ្រានយកទីក្រុងរ៉ូម។

នៅចុងសតវត្សទី ១១ សាកលវិទ្យាល័យ Bologna បានរើកកាយយកច្បាប់រ៉ូម៉ាំងពីដើមយកមកបង្រៀន។ ក្រោយមកសាកលវិទ្យាល័យផ្សេងៗទៀតនៅអឺរ៉ុប ក៏ចាប់ផ្តើមបង្រៀន "Corpus Juris Civilis" របស់ Justinian រហូតដល់ប្រព័ន្ធរ៉ូម៉ាំងត្រូវបានទទួលស្គាល់នៅឧបទ្វីបអឺរ៉ុប (Continental Europe) ដែលធ្វើអោយអឺរ៉ុបស្ទើរតែទទួលអនុវត្តប្រព័ន្ធច្បាប់ដូចគ្នាតែមួយដែលគេហៅថា "Jus Commune"។ ប្រព័ន្ធច្បាប់រ៉ូម៉ាំង ដែលគេទទួលយកមកអនុវត្តនេះ ភាគច្រើនទាក់ទងនឹងបុគ្គលភាព ទ្រព្យសម្បត្តិ កិច្ចសន្យា និង អំពើអនីត្យានុកូល ដែលសុទ្ធតែជាចង្កោមនៃនីតិឯកជន។ ហេតុនេះហើយ ទើបអ្នកច្បាប់ក្នុងប្រព័ន្ធ Civil Law តែងហៅ នីតិឯកជនថាជា droit civil ឬ Civil Law នេះតែម្តងដែលផ្តោតលើ "បុគ្គលភាព ទ្រព្យសម្បត្តិ និង កាតព្វកិច្ច"។ សព្វថ្ងៃនេះ ប្រទេសដែលប្រកាន់យកប្រព័ន្ធ Civil Law នៅបន្តអនុវត្តឥទ្ធិពលនៃការចងក្រងច្បាប់ជាក្រម (code) ដូចសម័យ Justinian ដែរ ដូចជា ក្រមរដ្ឋប្បវេណីរបស់បារាំងឆ្នាំ ១៨០៤ និង ក្រមរដ្ឋប្បវេណីអាឡឺម៉ង់ឆ្នាំ ១៨៩៦។ ព្រះចៅអធិរាជណាប៉ូឡេអុងរបស់បារាំង ពេលធ្វើសង្គ្រាមពង្រីកទឹកដី តែងស្លាយយកក្រមរដ្ឋប្បវេណីបារាំងទៅអនុវត្តលើទឹកដីទាំងនោះ។ ចំណែកឥទ្ធិពលនៃក្រមរដ្ឋប្បវេណីអាឡឺម៉ង់ ក៏បានលាតសន្ធឹងលើប្រទេសមួយចំនួនដែរ ដូចជាប្រទេសអូទ្រីស ប្រទេសស្វីស និង ប្រទេសអឺរ៉ុបខាងកើតមួយចំនួនទៀត មុនពេលការកកើតនៃសហភាពសូវៀត។ ឥទ្ធិពលរបស់អាឡឺម៉ង់ ក៏បានចាក់ឫសគល់នៅជប៉ុន កូរ៉េ និង តៃវ៉ាន់ផងដែរ។

## ការប្រៀបធៀបក្នុងវិធីសាស្ត្រគតិយុត្ត

### Case Law Vs. (French) La jurisprudence

នៅក្នុងបណ្តាប្រទេសដែលប្រកាន់យកប្រព័ន្ធ Common Law សេចក្តីសម្រេចរបស់តុលាការ (យុត្តិសាស្ត្រ) ជាប្រភពមួយយ៉ាងសំខាន់នៃនីតិ។ ដូចនេះ ការសិក្សាច្បាប់ក្នុងប្រព័ន្ធនេះ តែងចាប់ផ្តើមពីការវិភាគលើសាលក្រម (Case Law) ។ ដោយឡែក ក្នុងប្រព័ន្ធ Civil Law ការសិក្សាច្បាប់តែងចាប់ផ្តើមពីការវិភាគលើអត្ថបទច្បាប់តែម្តង។ ជាការពិតណាស់ សព្វថ្ងៃនេះ ភាពខុសគ្នារវាងប្រព័ន្ធទាំងពីរ កាន់តែរួមតូចទៅៗ ដោយសារក្នុងប្រព័ន្ធ Common Law មានការអនុម័តច្បាប់កាន់តែច្រើនឡើងៗ ក្នុងខណៈដែលប្រព័ន្ធ Civil Law ក៏ពឹងផ្អែកលើយុត្តិសាស្ត្រខ្លាំងឡើងៗដែរ។

ក្នុងប្រព័ន្ធ Civil Law របស់បារាំង សាលក្រមរបស់តុលាការពុំធ្វើអត្ថាធិប្បាយវែងអន្លាយទៅលើអង្គហេតុទេ តែច្រើនផ្តោតទៅលើគោលការណ៍ទូទៅនៃនីតិទៅវិញ (general principle of law)។ ជាក់ស្តែង សាលក្រមតុលាការបារាំងតែងសរសេរថា "យោងមាត្រា XX បានចែងថា.... យោងតាមគោលការណ៍ទូទៅនៃនីតិស្តីអំពី....តុលាការសម្រេច...."។ ដូចនេះ ក្នុងប្រព័ន្ធ Civil Law របស់បារាំង អ្នកច្បាប់ធ្វើការវិភាគលើសាលក្រម ដើម្បីស្វែងរកនិងបញ្ជាក់ពីអត្ថិភាពនៃគោលការណ៍ទូទៅនៃនីតិណាមួយ រួចយកមកធ្វើជាអំណះអំណាងក្នុងរឿងក្តីរបស់ខ្លួន។ ផ្ទុយទៅវិញ ក្នុងប្រព័ន្ធ Common Law សាលក្រមតុលាការតែងធ្វើអត្ថាធិប្បាយយ៉ាងក្បោះក្បាយទៅលើអង្គហេតុ និង អត្ថាធិប្បាយទៅលើ

យុត្តិសាស្ត្រដែលមានពីមុនមក ដើម្បីយកយុត្តិសាស្ត្រពីរឿងក្តីដែលមានពីមុននោះ មកអនុវត្តក្នុងរឿងក្តីដែលកំពុងដោះស្រាយកាលបើវាមានអង្គហេតុប្រហែលគ្នា។ និយាយម្យ៉ាងទៀតមានន័យថា យុត្តិសាស្ត្រពីមុន (សេចក្តីសម្រេចរបស់សាលាក្តីជាន់ខ្ពស់) មានអំណាចចាប់បង្ខំអោយអនុវត្តតាម។ នេះ ជាគោលការណ៍ដែលគេហៅថា “stare decisis”។

## ឥទ្ធិពលរបស់ Common Law នៅកម្ពុជា

ក្នុងការដោះស្រាយវិវាទការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងធ្វើការបកស្រាយអត្ថន័យនៃបញ្ញត្តិណាមួយដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួន (“សេចក្តីបង្គាប់អាជ្ញាកណ្តាល”)។ អ្វីដែលគួរអោយកត់សម្គាល់បំផុតនោះគឺនៅត្រង់ថាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្កើតលំនាំថ្មីដោយព្រមទទួលអនុវត្តតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនៗ ដែលទង្វើនេះបានក្លាយជាទម្លាប់ថ្មីក្នុងប្រពន្ធ័ច្បាប់កម្ពុជា។ ក្នុងស្ទើរគ្រប់សេចក្តីបង្គាប់អាជ្ញាកណ្តាល ត្រង់ផ្នែក *ហេតុផលនៃសេចក្តីសម្រេច* គេតែងសង្កេតឃើញឃ្លារដ៏មានអត្ថន័យនេះ ”*ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ*”។ ឃ្លារនេះមានន័យថាក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្តល់តម្លៃគតិយុត្តដល់ការបកស្រាយពីមុនៗរបស់ខ្លួន ក្នុងគោលបំណងបង្កើតជាយុត្តិសាស្ត្រជាក់លាក់តាមគោលការណ៍ stare decisis របស់ប្រពន្ធ័ Common Law។ យុត្តិសាស្ត្របង្កើតជាបណ្តុំវិធានដែលមានអានុភាពយកមកអនុវត្តក្នុងវិវាទក្រោយៗទៀត។ ឧទាហរណ៍ ទាក់ទងនឹងការបកស្រាយអត្ថន័យនៃប្រយោគ ”ក្រោមការគ្រប់គ្រងនិងដឹកនាំនៃនិយោជក” [11] (មាត្រា ២ នៃច្បាប់ស្តីពីការងារ ១៩៩៧) ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងឆ្នាំ ២០១៦ ក្នុងសេចក្តីបង្គាប់ ០៧៩/១៦ ចុះថ្ងៃ ២៧ ឧសភា ២០១៦ ប្រ៊ីធីស អ៊ីម៉េរីខិន ថឹប៉ែកខូ (ខេមបូឌា) លីមីធីត បានបន្តអនុវត្តតាមការបកស្រាយក្នុងសេចក្តីបង្គាប់ដែលខ្លួនបានចេញតាំងពីឆ្នាំ២០០៣ម្ល៉េះ។ ក្នុងសេចក្តីបង្គាប់ ០៧៩/១៦ នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសរសេរថា៖

> បន្ថែមពីនេះ ក្នុងសំណុំរឿងលេខ ១៧/០៣, ១៨/០៣-ហូ ហឹង និង ៨៤/០៨-ទ្រីនុងហ្កាល់ កូមា៉ា ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថានិយោជកមានសិទ្ធិ ក្នុងការចាត់ចែងនិងគ្រប់គ្រងក្រុមហ៊ុនរួមមានការផ្ទេរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយហើយនិងការផ្តល់អោយនូវលក្ខខណ្ឌមួយចំនួនដូចជា ៖ (១)-មិនកាត់ប្រាក់ឈ្នួល (២)- មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)- មិនផ្លូវវេនការងារពីថ្ងៃទៅយប់ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក។ (ទំព័រ២៥)

ដោយអនុទ្បោមតាមការបកស្រាយដែលបង្កើតលក្ខខណ្ឌទាំងបួនខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសេចក្តីបង្គាប់ ០៧៩/១៦ នេះបានសន្និដ្ឋានថាទោះបីជា៖

> ការប្តូរកន្លែងការងាររបស់ លោកប្រាក់ភក្តី មិននាំអោយមានការកែប្រែប្រាក់ឈ្នួល, វេនការងារ ឬជំនាញរបស់គាត់ … ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារយល់ឃើញថាការចាត់ចែងរបស់និយោជកដែលផ្លាស់ប្តូរកន្លែងការងាររបស់ លោកប្រាក់ភក្តី …គឺបានប៉ះពាល់ដល់លក្ខខណ្ឌទី២នៃលក្ខខណ្ឌទាំងបួនខាងលើ ហេតុនេះការប្រើសិទ្ធិចាត់ចែងនេះគឺមិនសមស្របនោះទេ។ ក្នុងករណីនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថានិយោជកគួរតែបានធ្វើការពិភាក្សាជាមួយ លោកប្រាក់ភក្តី ឱ្យមានការព្រមព្រៀងគ្នាជាមុនសិនមុននឹងសម្រេចផ្លាស់ប្តូរកន្លែងការងាររបស់គាត់ទៅខេត្តកំពង់ចាម។ (ទំព័រ២៦)

ជាការពិតណាស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំបានបកស្រាយថា ត្រូវមានការព្រមព្រៀងគ្នាជាមុនសម្រាប់គ្រប់ករណីនោះទេ គឺអ្វីៗត្រូវពិចារណាពីអង្គហេតុជាក់ស្តែង។ ការពឹងលើអង្គហេតុនិងការផ្តល់តម្លៃគតិយុត្តដល់ការបកស្រាយក្នុងសេចក្តីសម្រេចមុនៗគឺជាសក្ខីភាពនៃការទទួលយកឥទ្ធិពលរបស់ Common Law។

---

[11] សូមអានបន្ថែម Virak Prum (2016). *Subordination in Employment Relationship*. Available on CamEd Business School’s website via https://drive.google.com/file/d/0BxOaYhs9pC6QSzZGMHZsNlBVZ1U/view

ដូចគ្នានេះដែរក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអនុវត្តយុត្តិសាស្ត្ររបស់ខ្លួន ក្នុងការបកស្រាយបញ្ញត្តិផ្សេងៗជាច្រើនទៀតនៃច្បាប់ការងារដូចជាបញ្ញត្តិទាក់ទងនឹងសិទ្ធិព្យួរការងារដោយមូលហេតុមានផលលំបាកខាងសេដ្ឋកិច្ចជាដើម។ ក្នុងរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបន្តអនុវត្តការបកស្រាយរបស់ខ្លួនក្នុងរយៈពេលមួយទសវត្សជាបន្តបន្ទាប់ហើយបានបង្កើតលក្ខខណ្ឌចំនួនបួនគឺៈ (១) រយៈពេលព្យួរមិនត្រូវលើសពីរខែ (២) ត្រូវជូនដំណឹងទៅអធិការកិច្ចការងារ (៣) ត្រូវទទួលបានការអនុញ្ញាតជាមុន និង (៤) ការអនុញ្ញាតត្រូវជាលាយលក្ខអក្សរ។ [12] ជាក់ស្តែងក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦០/១៤ ចុះថ្ងៃ ៩ កក្កដា ២០១៤ ទាក់ទងនឹងការព្យួរការងាររយៈពេល ១ ខែក្រុមប្រឹក្សាអាជ្ញាកណ្តាលបានប្រើអំណះអំណាងដោយឈរលើការសម្រេចពីលើកមុនលេខ ០៨/០៧ ចុះថ្ងៃ ២០ កុម្ភៈ ២០០៧ ដែលបានបកស្រាយប្រយោគ "ស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការការងារ" ថាបូកបញ្ចូលលក្ខខណ្ឌពីរគឺត្រូវជូនដំណឹងអធិការការងារនិងត្រូវរងចាំទទួលបានការអនុញ្ញាតជាមុនសិនចំពោះការចង់ព្យួរ។ សេចក្តីបង្គាប់ឆ្នាំ ២០០៧ នេះត្រូវបានប្រើជាញឹកញាប់ ហើយមានមូលដ្ឋានពីសេចក្តីបង្គាប់ចាស់ៗឆ្នាំ២០០៥។ [13] ដូច្នេះមានវិធានយុត្តិសាស្ត្រច្បាស់លាស់ដែលទាមទារអោយមានការជូនដំណឹងទៅអធិការការងារជាមុននិងទាមទារអោយទទួលបានការអនុញ្ញាតជាមុនថែមទៀត បើពុំនោះទេការព្យួរការងារនឹងមិនមានភាពស្របច្បាប់ឡើយ។ លើសពីនេះទៀត សេចក្តីបង្គាប់លេខ ១៦០/១៤ បានទាមទារអោយការអនុញ្ញាតពីអធិការការងារត្រូវតែជាលាយលក្ខអក្សរថែមទៀត (ទំព័រ១១នៃសេចក្តីបង្គាប់) បានន័យថានិយោជកមិនអាចសំអាងលើការអនុញ្ញាតដោយផ្ទាល់មាត់បានឡើយ។

## សេចក្តីសន្និដ្ឋាន

ក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីសម្រេចស្ទើររាល់ថ្ងៃ ដោយធ្វើការបកស្រាយអត្ថន័យនៃបញ្ញត្តិនានានៃច្បាប់ការងារដើម្បីធានាអោយមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពដែលត្រូវឈរលើកត្តាសំខាន់ពីរគឺ តម្លាភាពនិងភាពអាចដឹងជាមុនបាន។ ក្នុងបច្ចេកទេសនីតិសាស្ត្រ ប្រព័ន្ធច្បាប់ដែលអាចបង្កើតកត្តាទាំងពីរនេះបានល្អជាងគេគឺប្រព័ន្ធដែលគោរពតាមយុត្តិសាស្ត្របានខ្ជាប់ខ្ជួន ពោលគឺប្រព័ន្ធ Common Law នេះឯង។[14] ប្រព័ន្ធនេះផ្តល់ទំនុកចិត្តខ្ពស់ដល់វិនិយោគិនព្រោះវិនិយោគិនដែលគោរពច្បាប់ហើយមានភាពប្រយ័ត្នប្រយែងតែងតែចង់ដឹងថាពេលមានវិវាទ តើស្ថាប័នដោះស្រាយវិវាទនឹងរេទៅខាងណា។ ការយល់ដឹងពីយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងជួយអោយវិនិយោគិនតាក់តែងកិច្ចសន្យាការងារបានល្អ ដែលអាចយកទៅអនុវត្តបាននិងជួយអោយពួកគេអាចដឹកនាំនិយោជិតប្រកប ដោយទំនុកចិត្តខ្ពស់ជាងមុន។ ម៉្យាងទៀតក្នុងករណីដែលច្បាប់ពុំមានចែង ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចឈរលើគោលការណ៍សមធម៌ដើម្បីសម្រេចសេចក្តីបាន។ តាំងពីឆ្នាំ២០០៣មក ក្នុងចំណោមស្ថាប័នដោះស្រាយវិវាទទាំងអស់នៅកម្ពុជា ក្រុមប្រឹក្សាអាជ្ញាកណ្តាលជាស្ថាប័នដែលនាំមុខគេក្នុងការទទួលយកទ្រឹស្តី stare decisis ពីប្រព័ន្ធ Common Law មកអនុវត្តដោយបានចេញជាយុត្តិសាស្ត្រជាបន្តបន្ទាប់។ ចរន្តដ៏ល្អនេះនឹងបន្តទៅមុខទៀត ហើយត្រូវតែបន្តទៅមុខទៀតដើម្បីជួយបង្កើនសុវត្ថិភាពគតិយុត្តក្នុងវិស័យការងារ។ ចង់ឬមិនចង់ ទាំងច្បាប់ ទាំងយុត្តិសាស្ត្រគឺជាលទ្ធផលនៃការបកស្រាយទាំងអស់។

---

[12] សូមអាន Virak Prum (2017) *Suspension of Employment Contract*. Available on CamEd Business School's website via https://drive.google.com/file/d/0BxOaYhs9pC6QWklrcV9UNGl4Z1k/view

[13] សេចក្តីបង្គាប់លេខ ០៨/០៧ ចុះថ្ងៃទី២០កុម្ភៈ២០០៧នេះធ្វើការចង្អុលបង្ហាញទៅសេចក្តីបង្គាប់ពីរទៀតឆ្នាំ២០០៥ គឺលេខ២២/០៥និងលេខ៧២/០៥។ សេចក្តីបង្គាប់អាជ្ញាកណ្តាលមាននៅលើគេហទំព័រនេះ http://www.arbitrationcouncil.org/en/ac-decisions/arbitral-decisions

[14] និយាយបែបនេះ មិនមែនមានន័យថាប្រព័ន្ធ Civil Law មានភាពទន់ខ្សោយខាងផ្នែកយុត្តិសាស្ត្រនោះទេ។ ស្រុកបារាំងដែលជាប្រទេសគំរូខាង Civil Law មានយុត្តិសាស្ត្រដ៏ច្រើនសន្ធឹកសន្ធាប់។ អ្វីដែលខុសគ្នាគឺនៅត្រង់មូលដ្ឋានបីដែលបានបង្ហាញខាងលើ។

## REFERENCES

Chevron U.S.A., Inc. v. Natural Resources Defense Council Inc., 467 U.S. 837 (1984).

Jane Ginsburg (2014) *Legal Methods*. New York: Foundation Press (University casebook series).

Jean Waline (2016) *Droit Administratif*, 26 edi (Précis). Paris: Dalloz.

Jerry Mashaw (1983) *"Rights" in the Federal Administrative State*, 92 Yale Law Journal.

Paul Verkeuil (2006) *"Private Law Limitations on Privatization of Government Functions,"* 84, N.C.L. Review.

Virak Prum (2016) *Subordination in Employment Relationship*. Available on CamEd Business School's website via https://drive.google.com/file/d/0BxOaYhs9pC6QSzZGMHZsNlBVZ1U/view

Virak Prum (2017) *Suspension of Employment Contract*. Available on CamEd Business School's website via https://drive.google.com/file/d/0BxOaYhs9pC6QWklrcV9UNGl4Z1k/view

Yves Gaudemet (2015) *Droit Administratif*, 21 edi (Manuel). Paris: LGDJ.